ដំណឹងល្អ

**លោកុប្បត្តិ ១:១ កាលដើមដំបូងឡើយ ព្រះបានបង្កើតផ្ទៃមេឃនឹងផែនដី ។**

នៅពេលដែលយើងរៀនអំពីដំណឹងល្អ មុនដំបូងពួកយើងត្រូវតែដឹងថា នៅផែនដីនេះ ហើយនិងគ្រប់របស់ទាំងអស់មានគោលបំណង មិនមែនកើតឡើងដោយចៃដន្យទេ។ បន្ទាប់មកនេះ យើងនឹងរៀនអំពីលំដាប់លំដោយនៃការដែលព្រះបានបង្កើតរបស់របរទាំងអស់នៅលើផែនដី នៅថ្ងៃទី៣ ព្រះបានបង្កើតរុក្ខជាតិ និងតិណជាតិឱ្យមានគ្រាប់តាមពូជរបស់វា បន្ទាប់មកក៏មានសត្វច្រើនប្រភេទផ្សេងៗពីគ្នា។ នេះទាំងអស់ដែលបានបង្កើតមក វាមានសមត្ថភាពតាមពូជរបស់វា ដើម្បីអាចបន្តពូជ តាមពូជនិមួយៗដូចគ្នារហូត។ ឧទាហរណ៍ បើមុនដំបូងជាត្រី វាក៏បង្កើតត្រី ហើយស្វាក៏បង្កើតស្វាដែរ ក្រោយមកព្រះបានបង្កើតមនុស្សដាច់ដោយឡែកពីសត្វ។

**លោកុប្បត្តិ ១:២៧ ទ្រង់ក៏បង្កើតមនុស្សឱ្យដូចរូបអង្គទ្រង់ គឺបានបង្កើតគេឱ្យចំនឹងរូបអង្គទ្រង់នោះឯង ក៏បង្កើតគេឡើងជាប្រុសជាស្រី**

លក្ខណៈរបស់ព្រះចំពោះមនុស្ស គឺទ្រង់មានព្រះគុណ និងសេចក្ដីសប្បុរស

**លោកុប្បត្តិ ១:២៨ ទ្រង់ប្រទានពរដល់គេ ហើយមានបន្ទូលថា ចូរបង្កើតកូនឱ្យចំរើនជាច្រើនឡើង ឱ្យមានពេញពាសលើផែនដីចុះ ត្រូវបង្ក្រាបផែនដីហើយមានអំណាចលើត្រីសមុទ្រ សត្វហើរលើអាកាស នឹងជីវិតផងទាំងឡាយដែលកំរើកនៅផែនដីផង**

ពីខាងលើ យើងអាចដឹងច្បាស់ថា មនុស្សមិនមែនកើតមក ពីពូជរបស់សត្វនោះទេ។ ថែមទៀត ពីអត្ថបទនេះ ជីវិតរបស់មនុស្ស មិនមែនគ្មានតំឡៃនោះទេ។ ប្រាកដមែនជីវិតរបស់មនុស្សមានតំឡៃ ហើយនិងព្រះបានប្រទានការទទួលខុសត្រូវចំពោះមនុស្សផងដែរ។

យើងអាចមានជោគជ័យបាន ដោយការបំពេញតួនាទីដែលព្រះបានប្រទានឱ្យ តាមការស្ដាប់បញ្ញត្តិរបស់អ្នកបង្កើត។ កន្លងយូរមកហើយ យើងសិក្សាថា ការមិនស្ដាប់បង្គាប់ ដោយបុរសលើកទីមួយមានលទ្ធផលអាក្រក់ខ្លាំង ហើយមនុស្សទាំងអស់ក៏ទទួលលទ្ធផលអាក្រក់នោះដែរ ដូចជាព្រះបន្ទូលថា

**រ៉ូម ៥:១២ ដូច្នេះ ដែលបាបបានចូលមកក្នុងលោកីយ ដោយសារមនុស្សតែម្នាក់ ហើយក៏មានសេចក្ដីស្លាប់ចូលមកដែរ ដោយសារអំពើបាបនោះជាយ៉ាងណា នោះសេចក្ដីស្លាប់បានឆ្លងរាលដាល ដល់មនុស្សគ្រប់គ្នាយ៉ាងនោះដែរ ដ្បិតគ្រប់គ្នាបានធ្វើបាបហើយ**

អំពើបាបមានន័យថា " ដាច់ចេញពីសេចក្ដីសុចរិតរបស់ព្រះ" ពីព្រោះព្រះទ្រង់គ្រប់លក្ខណ៏។ ពួកយើងទាំងអស់គ្នាជាពូជរបស់អ័ដាម ហើយអ័ដាមមិនស្ដាប់បង្គាប់ព្រះយេហូវ៉ា ពីព្រោះពួកយើងជាពូជរបស់អ័ដាម អំពើបាបបានឆ្លងពីគាត់មកដល់ពួកយើង។ ដូច្នេះ ពួកយើងអាចធ្វើល្អខ្លះ អាក្រក់ខ្លះ សព្វថ្ងៃនេះសំរាប់ពួកយើងមិនអាចធ្វើតាមសេក្ដីសុចរិតរបស់ព្រះរហូតបានទេ។

**រ៉ូម ៣:១០**

**១០ដូចមានសេចក្ដីចែងទុកមកថា "គ្មានអ្នកណាសុចរិតសោះ សូម្បីតែម្នាក់ក៏គ្មានផង**

ជាការពិតពួកយើងមានសមត្ថភាពអាចធ្វើល្អ និយាយល្អ ប្រព្រឹត្តល្អបាន។ យ៉ាងណាក៏ដោយ ពីព្រោះយើងជាអ្នកមានបាប យើងមិនអាចធ្វើល្អរហូតបានទេ ព្រះបន្ទូលរបស់ថា

**រ៉ូម ៣:២៣**

**២៣ពីព្រោះគ្រប់គ្នាបានធ្វើបាបហើយខ្វះមិនដល់សិរីល្អនៃព្រះ**

គ្មានមនុស្សលោកដែលអត់មានបញ្ហានេះ ហើយយើងមិនអាចរួចពីបញ្ហានេះដែរ គ្មានការប្រព្រឹត្តល្អ ឬសាសនាមួយណាក៏ដោយ ដែលអាចជួយមនុស្សចេញពីអំពើបាបបានទេ ពីព្រោះការប្រព្រឹត្តល្អរបស់ពួកយើងកើតមកពីលក្ខណៈរបស់អ័ដាម។ ដំណឹងល្អមានន័យថា ព្រះយេស៊ូវគ្រីស្ទដែលជាអ្នកបង្កើតផែនដី និងអ្វីដែលមាននៅផែនដីនេះផង ទ្រង់នឹងសង្គ្រោះយើងដោយអង្គទ្រង់ផ្ទាល់។ គ្មានសាសនាណាមួយសោះ ដែលអាចលោះយើងពីអំពើបាបបានទេ មានតែព្រះយេស៊ូវគ្រីស្ទដែលជាអ្នកបង្កើតរបស់យើងដែលអាចធ្វើបាន ។

**ទីតុស ៣:៥-៦**

**៥នោះទ្រង់បានជួយសង្គ្រោះយើង មិនមែនដោយការដែលយើងបានប្រព្រឹត្តដោយសុចរិតនោះទេ គឺដោយសេចក្ដីមេត្តាករុណារបស់ទ្រង់វិញ ដោយសារការសំអាតនៃសេចក្ដីកើតជាថ្មី ហើយការប្រោសជាថ្មីឡើងវិញ**

**នៃព្រះវិញ្ញាណបរិសុទ្ធ ៦ដែលទ្រង់បានចាក់មកលើយើងជាបរិបូរ ដោយសារព្រះយេស៊ូវគ្រីស្ទ ជាព្រះអង្គ**
**សង្គ្រោះនៃយើង**

ហោរាអេសាយបានកត់ទុករឿងអំពីបញ្ហារបស់មនុស្ស នឹងដំណោះស្រាយរបស់ព្រះ

**អេសាយ ៥៣:៦**
**៦យើងទាំងអស់គ្នាបានទាសចេញដូចជាចៀម គឺយើងបានបែរចេញទៅតាមផ្លូវយើងរៀងខ្លួន ហើយ**
**ព្រះយេហូវ៉ាបានទំលាក់អំពើទុច្ចរិតរបស់យើងទាំងអស់គ្នាទៅលើទ្រង់។**

ហោរាអសាយបានទាយថា ព្រះនឹងប្រទានយញ្ញបូជាល្អដែលនឹងទទួលទណ្ឌកម្មសំរាប់អំពើបាបរបស់មនុស្ស ទាំងអស់។ ព្រះយេស៊ូវគ្រីស្ទគឺជាព្រះរាជបុត្រារបស់ព្រះ បានធ្វើបន្ទាល់ពីសេចក្តីពិតនេះថា

**យ៉ូហាន ៣:១៦**
**១៦ដ្បិតព្រះទ្រង់ស្រឡាញ់មនុស្សលោក ដល់ម៉្លេះបានជាទ្រង់ប្រទានព្រះរាជបុត្រាទ្រង់តែ១ ដើម្បីឱ្យអ្នកណា**
**ដែលជឿដល់ព្រះរាជបុត្រានោះ មិនត្រូវវិនាសឡើយ គឺឱ្យមានជីវិតអស់កល្បជានិច្ចវិញ**

នេះជាដំណឹងល្អអំពីអ្វីដែលព្រះយេស៊ូវគ្រីស្ទធ្វើសំរាប់ពួកយើង

**កូរិនថូសទី១ ១៥:៣-៤**
**៣ដ្បិតមុនដំបូង ខ្ញុំបានប្រាប់មកអ្នករាល់គ្នា តាមសេចក្តីដែលខ្ញុំបានទទួលដែរ គឺថាព្រះគ្រីស្ទបានសុគត**
**ដោយព្រោះបាបរបស់យើងរាល់គ្នា តាមបទគម្ពីរ ៤ហើយថា ទ្រង់ត្រូវគេបញ្ចុះក្នុងផ្នូរ រួចដល់ថ្ងៃទី៣ នោះ**
**ទ្រង់មានព្រះជន្មរស់ឡើងវិញ ក៏តាមបទគម្ពីរ**

នេះជាអត្ថន័យពីដំណឹងល្អ ព្រះយេស៊ូវគ្រីស្ទជាព្រះរាជបុត្រា ទ្រង់សុគតនៅលើឈើឆ្កាងហើយនឹងទទួលទណ្ឌកម្មសំរាប់អំពើបាបរបស់យើង

**កូរិនថូសទី២ ៥:២១**
**២១ដ្បិតឯព្រះអង្គដែលមិនបានស្គាល់បាបសោះ នោះព្រះទ្រង់បានធ្វើឱ្យត្រឡប់ជាតួបាប ជំនួសយើងរាល់គ្នា**
**វិញ ដើម្បីឱ្យយើងរាល់គ្នាបានត្រឡប់ទៅជាសេចក្តីសុចរិតរបស់ព្រះ ដោយនូវព្រះអង្គនោះឯង។**

**ពេត្រុសទី១ ២:២៤**
**២៤ ទ្រង់បានផ្ទុកអំពើបាបរបស់យើងរាល់គ្នា នៅលើរូបអង្គទ្រង់ ជាប់លើឈើឆ្កាង ដើម្បីឱ្យយើងបានរស់ខាងឯសេចក្ដីសុចរិត ដោយបានស្លាប់ខាងឯអំពើបាបហើយ គឺដោយស្នាមជាំរបស់ទ្រង់ ដែលអ្នករាល់គ្នាបានជា**

ព្រះយេស៊ូវគ្រីស្ទសុគត បានបញ្ចុះនៅក្នុងផ្នូរ៣យប់៣ថ្ងៃ ហើយក្រោយនោះទ្រង់មានព្រះជន្មរស់ឡើងវិញ ។ព្រះយេស៊ូវគ្រីស្ទសុគត ដើម្បីប្រោសលោះយើងពីអំពើបាប ហើយរស់ឡើងវិញ ដើម្បីសំដែងថា ទ្រង់មានជ័យជំនះលើសេចក្ដីស្លាប់ហើយ។ ដូច្នេះ ពួកយើងដែលទទួលជឿដល់ព្រះយេស៊ូវគ្រីស្ទ យើងនឹងទទួលការអត់ទោសអំពើបាប ព្រមទាំងមានជីវិតអស់កល្បជានិច្ចផងដែរ។

សូមគិតពិចារណា អំពីប្អូនប្រុសរបស់ស្រីម្នាក់ដែលបានស្លាប់ហើយ

**យ៉ូហាន ១១:២៥-២៦**
**២៥ ព្រះយេស៊ូវមានបន្ទូលទៅនាងថា ខ្ញុំជាសេចក្ដីរស់ឡើងវិញ ហើយជាជីវិត អ្នកណាដែលជឿដល់ខ្ញុំ ទោះ**
**បើបានស្លាប់ហើយ គង់តែនឹងរស់ឡើងវិញដែរ ២៦ ឯអ្នកណាដែលរស់នៅ ហើយជឿដល់ខ្ញុំ នោះមិនត្រូវស្លាប់**
**ឡើយ នាងជឿសេចក្ដីនេះឬទេ**

ទីសំគាល់នេះធំអស្ចារ្យ ដែលព្រះយេស៊ូវគ្រីស្ទបានធ្វើសម្រេចជិត ២ពាន់ឆ្នាំមុន ក្រោយនោះ យើងអាចឃើញរឿងនេះនៅក្នុងព្រះគម្ពីរ នេះជាដំណឹងល្អ។ ឥឡូវនេះយើងអាចទទួលជឿដល់ព្រះយេស៊ូវគ្រីស្ទ មិនមែនដោយការកាន់តាមសាសនា ប៉ុន្តែដោយសេចក្ដីជំនឿវិញ

**អេភេសូរ ២:៨_៩**
**៨ ដ្បិតគឺដោយព្រះគុណ ដែលអ្នករាល់គ្នាបានសង្គ្រោះដោយសារសេចក្ដីជំនឿ ហើយសេចក្ដីនោះក៏មិនមែន**
**កើតពីអ្នករាល់គ្នាដែរ គឺជាអំណោយទានរបស់ព្រះវិញ ៩ ក៏មិនមែនដោយការប្រព្រឹត្តដែរ ក្រែងអ្នកណាអួតខ្លួន**

ប្រហែលអ្នកស្មានថា តើខ្ញុំត្រូវធ្វើអ្វីដើម្បីបានសេចក្ដីសង្គ្រោះ ហើយនឹងព្រះអត់ទោសអំពើបាបរបស់ខ្ញុំ?
មានចំឡើយដែលមកពីព្រះគម្ពីរនៅខាងក្រោមនេះ

**កិច្ចការ ១៦:៣១**
**៣១ គេក៏ប្រាប់គាត់ថា ចូរជឿដល់ព្រះអម្ចាស់យេស៊ូវគ្រីស្ទទៅ នោះនឹងបានសង្គ្រោះហើយ ព្រមទាំងពួកគ្រួសារលោកផង**

អំពីព្រះយេស៊ូវគ្រីស្ទ ព្រះគម្ពីរថា

**យ៉ូហាន ១:១២**
**១២ ប៉ុន្តែអស់អ្នកណាដែលទទួលទ្រង់ គឺអស់អ្នកដែលជឿដល់ព្រះនាមទ្រង់ នោះទ្រង់បានប្រទានអំណាច ឲ្យបានត្រឡប់ជាកូនព្រះ**

សាវកប៉ុលថា
**រ៉ូម ១០:៩-១០**
**៩ បើមាត់អ្នកនឹងទទួលថ្លែងប្រាប់ពីព្រះអម្ចាស់យេស៊ូវ ហើយអ្នកជឿក្នុងចិត្តថា ព្រះបានប្រោសឲ្យទ្រង់រស់ពីស្លាប់ឡើងវិញ នោះអ្នកនឹងបានសង្គ្រោះពិត**
**១០ ដ្បិតយើងបានសុចរិត ដោយមានចិត្តជឿ ហើយក៏បានសង្គ្រោះដោយមាត់ទទួលថ្លែងប្រាប**

ថ្ងៃនេះយើងអាចទទួលជឿដល់ព្រះ ហើយនឹងទទួលជីវិតអស់កល្បជានិច្ច ដោយសេចក្តីជំនឿជឿលើព្រះយេស៊ូវគ្រីស្ទជាព្រះរាជបុត្រារបស់ព្រះ

**រ៉ូម ១០:១៣**
**១៣ ហើយគ្រប់គ្នា គឺអស់អ្នកណា ដែលអំពាវនាវដល់ព្រះនាមព្រះអម្ចាស់ នោះនឹងបានសង្គ្រោះ**